ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និង សុក្រឹតការវិជ្ជាជីវៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៩.អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១

សម្រេច

<u>មាត្រា ១</u> .-

ត្រូវបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដោយកំណត់ឈ្មោះថា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ។

<u>មាត្រា ២</u> .-

មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រុមប្រឹក្សាគណៈមេធាវី និងក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងយុត្តិធម៌ ។

មាត្រា ៣ ..

មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការ វិជ្ជាជីវៈមេធាវី ត្រូវមានបទបញ្ជាផ្ទៃក្នុងមួយ ដែលកំណត់ នូវលក្ខខណ្ឌក្នុងដំណើរការរបស់មជ្ឈមណ្ឌលនេះ ។

មាត្រា ៤ ..

ក្រុមប្រឹក្សាគណៈមេធាវី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ តំណាង ជាអ្នកកំណត់នូវកម្មវិធីសិក្សា និងបែបបទក្នុងការប្រឡងចូល និងការប្រឡងយកវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។

គណៈមេប្រយោគក្នុងការប្រឡងចូល និងការប្រឡងយកវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះ ត្រូវមានសមាជិក ចំនួន ៩ រូប ហើយដែលមានសមាសភាព ដូចតទៅ :

-ប្រធានគណៈមេធាវី		ប្រធាន
-តំណាងក្រសួងយុត្តិធម៌	០១ រូប	អនុប្រធាន
-សមាជិកក្រុមប្រឹក្សាគណៈមេធាវី	០៤ រូប	សមាជិក
-ចៅក្រម	០១ រូប	សមាជិក
-សាស្ត្រាចារ្យច្បាប់ តំណាងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច	០១ រូប	សមាជិក
-តំណាងក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី	០១ រូប	សមាជិក

គណៈមេប្រយោគខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

មាត្រា ៥ ..

ប្រភពធនធាន និងថវិកានៃមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី ត្រូវបានមកពី :

-គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
-ចំណូលក្នុងការសុំចុះឈ្មោះចូលរៀនរបស់សិស្សមេធាវីកម្មសិក្សា
-ចំណូលក្នុងការសុំចុះឈ្មោះបេក្ខជនប្រឡង
-ជំនួយ និងប្រាក់ឧបត្ថម្ភពីសហគមន៍ជាតិ អន្តរជាតិ អង្គការផ្តល់ជំនួយនានា និងអំណោយរាជរដ្ឋាភិបាល ។

មាត្រា ៦ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច តាមភារៈកិច្ចរៀង ១ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-កាលប្បវត្តិ-ឯកសារ